00448743

**Declassified to Public**
**12 April 2013**

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 08 / 02 / 2010
មន្ត្រីមទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

ការពារ: D335/2

ភ្នំពេញ ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១០

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 05 / 02 / 2010
ម៉ោង (Time/Heure): 14:15
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**គោរពជូនលោកសហចៅក្រមស៊ើបអង្កេត**
**លោក យូ ប៊ុនឡេង**
**លោក** MARCEL LEMONDE
ភ្នំពេញ កម្ពុជា

*សំណុំរឿងស៊ើបអង្កេតលេខ 002/19-09-2007*

**កម្មវត្ថុ ៖ ចម្លើយតបទៅនឹង "ដីកាសម្រេចលើសំណើសុំពន្យារយៈពេលកំណត់ ដែលដាក់ដោយលោក ខៀវ សំផន"**

លោកសហចៅក្រមជាទីគោរព

នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០១០ សហមេធាវីការពារក្តី បានស្នើសុំដល់ការិយាល័យរបស់លោក សូមឱ្យគិតរយៈពេលកំណត់៣០ថ្ងៃ បន្ទាប់ពីសេចក្តីជូនដំណឹងបិទការស៊ើបអង្កេត ចាប់ពីត្រឹមពេលលោក ខៀវ សំផន ទទួលបានរាល់ដីកាសម្រេចទាំងអស់ និងរាល់សេចក្តីសន្និដ្ឋានទាំងអស់របស់ភាគីនានា ជាភាសាការងារទាំងពីររបស់គាត់។[1]

នៅក្នុងដីកាសម្រេច ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១០ ការិយាល័យរបស់លោក ចាត់ទុកថា សំណើសុំពន្យាពេលនេះ មានហេតុផលត្រឹមត្រូវ ប៉ុន្តែរយៈពេលកំណត់៣០ថ្ងៃនេះគួរតែគិតចាប់ពីពេលទទួលបានជាភាសាខ្មែរនូវដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតតែប៉ុណ្ណោះ។[2]

---

[1] សំណើសុំពន្យាពេលកំណត់ដើម្បីដាក់សំណើសុំបើកកិច្ចស៊ើបអង្កេតជាយថាហេតុណាមួយ បន្ទាប់ពីបានជូនដំណឹងពីការបិទការស៊ើបសួរ ថ្ងៃទី២១ ខែមករា ឆ្នាំ២០១០ *ឯកសារតុលាការលេខ D335*

[2] ដីកាសម្រេចលើសំណើសុំពន្យាររយៈពេលកំណត់ ដែលដាក់ដោយលោកខៀវ សំផន ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១០ *ឯកសារតុលាការលេខ D335/1*

00448744

ឯកសារ D 335/2

ក្នុងន័យនោះ ការិយាល័យរបស់លោកទទួលស្គាល់យ៉ាងស្ងៀមស្ងាត់ថា ការរៀបចំសំណើសុំបើកកិច្ចស៊ើបសួរបន្ថែម ទាក់ទងទៅនឹងការវិភាគលើខ្លឹមសារ និងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត (និងសេចក្តីសន្និដ្ឋានរបស់ភាគីនានា ដែលនាំឱ្យមានចេញសេចក្តីសម្រេចទាំងនោះ) មុនពេលជូនដំណឹងបិទការស៊ើបអង្កេត។ ក៏ប៉ុន្តែ ការជូនដំណឹងអំពីឯកសារទាំងនោះអាចចាត់ទុកថា មានលក្ខណៈជាផ្លូវការបាន (ហើយបើតាមពាក្យពេចន៍ផ្ទាល់របស់លោក LEMONDE) គឺចាប់រាប់ពីថ្ងៃដែលជនដែលទទួលរងការចោទបានទទួលបានឯកសារទាំងនោះជាភាសាដែលខ្លួនជ្រើសរើស ដើម្បីធានាការការពារក្តីរបស់គាត់ បន្ថែមពីលើភាសាខ្មែរ។ ការបកប្រែឯកសារទាំងនេះ គឺជាកាតព្វកិច្ច (ហើយនៅក្នុងករណីនេះ វាជាលក្ខខណ្ឌកំណត់កាលបរិច្ឆេទនៃការពន្យាពេលកំណត់៣០ថ្ងៃ)។ នេះគឺជាសិទ្ធិរបស់ជនត្រូវចោទ ផ្តល់ដោយអង្គបុរេជំនុំជម្រះ ហើយយើងសូមស្រង់យកសេចក្តីសម្រេច ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៨ ក្នុងកថាខណ្ឌ ៣៧ និង៣៨[3]៖

៣៧. ដីកាសម្រេចស្តីពីការបកប្រែចែងថា ជនត្រូវចោទមានសិទ្ធិទទួលបានការបកប្រែនូវឯកសារដូចខាងក្រោម ទៅជាភាសាបារាំង៖

- ដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត
- ភស្តុតាង ដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះនឹងយកមកធ្វើជាមូលដ្ឋានសម្អាង
- ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា
- លេខយោង និងតារាងអក្សររៀងនៃអង្គហេតុ ដែលដីកាទាំងនេះសម្អាងលើ (ជាក់ស្តែងគឺឯកសារ D3 និង D3/I-V)
- សេចក្តីសម្រេច និងដីកាទាំងអស់របស់តុលាការ និង
- ឯកសារទាំងអស់ដែលភាគីបានដាក់ជូននៅចំពោះមុខ អ.វ.ត.ក. ដូចមានចែងនៅក្នុងមាត្រា ៧(១) នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក។[២៣]

៣៨. យោងតាមដីកាសម្រេចស្តីពីការបកប្រែ ឯកសារទាំងនេះ ត្រូវបកប្រែជាភាសាខ្មែរផងដែរ ដែលជាភាសាកំណើតរបស់ជនត្រូវចោទ។

---

[3] ដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់លោកខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចស្តីពីការកំណត់សិទ្ធិ និងកាតព្វកិច្ចរបស់ភាគី ទាក់ទងការបកប្រែ ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៨ *ឯកសារតុលាការលេខ A190/I/20*

00448745

ឯកសារ D 335/2

៣៩. សហចៅក្រមស៊ើបអង្កេតបញ្ជាក់ថា ដីកាសម្រេចនេះ បានធ្វើឡើងក្នុងគោលបំណងកំណត់សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីក្នុងអំឡុងកិច្ចស៊ើបសួរ និង "ក្នុងគោលបំណងឱ្យអង្គជំនុំជម្រះសាលាដំបូងនៅពេលដែលទទួលបានសំណុំរឿង រៀបចំចាត់ចែងលើសេចក្តីត្រូវការនៃការបកប្រែសម្រាប់សវនាការនានា ដើម្បីជាប្រយោជន៍ដល់ការគ្រប់គ្រងល្អរបស់តុលាការ និងសិទ្ធិទទួលបាននូវការកាត់សេចក្តីដោយយុត្តិធម៌។"[២៨]

ហេតុនេះ ដីកាសម្រេច ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១០ មានលក្ខណៈផ្ទុយយ៉ាងជាក់ច្បាស់ទៅនឹងច្បាប់អនុវត្ត ដែលរំលោភទៅលើសិទ្ធិរបស់លោកខៀវ សំផន ដោយឥតអៀនខ្មាស ហើយនាំឱ្យគាត់ស្ថិតនៅក្នុងស្ថានភាពវិសមភាពយ៉ាងខ្លាំងជាមួយនឹងការិយាល័យសហព្រះរាជអាជ្ញា។

យើងសូមលោកសហចៅក្រមស៊ើបអង្កេតមេត្តាចាត់វិធានការពិនិត្យទៅលើផលប៉ះពាល់ដែលបណ្តាលមកពីសេចក្តីសម្រេចបែបនេះចំពោះមុខសមភាពនៃនីតិវិធី និងសូមមេត្តាពិចារណាឡើងវិញលើសេចក្តីសន្និដ្ឋានរបស់លោកឱ្យបានឆាប់រហ័ស។

សូមលោកសហចៅក្រមទាំងពីរ ទទួល នូវការគោរពរាប់អានអំពីយើង។

ជំនួសសហមេធាវីការពារក្តីទាំងពីរ

**លោកមេធាវី សា សូវាន**